ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ............................អពដ

# សេចក្តីប្រកាសព័ត៌មាន
## កិច្ចប្រជុំស្តីអំពី
## សរុបលទ្ធផលការងារសារពើពន្ធប្រចាំខែ កញ្ញា ឆ្នាំ ២០១៣

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ ២០១៣ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបការងារសារពើពន្ធប្រចាំខែកញ្ញា ឆ្នាំ២០១៣ របស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពរបស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃ អគ្គនាយកដ្ឋានពន្ធដារ ហើយមានការចូលរួមឯកឧត្តមអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន អនុប្រធាននាយកដ្ឋាន លោកប្រធានសាខាពន្ធដារខណ្ឌទាំង៧នៅរាជធានីភ្នំពេញ និងសាខាពន្ធដារខេត្តទាំង២៣ទូទាំងប្រទេស។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃ អគ្គនាយកដ្ឋានពន្ធដារ បានសំដែងអំណរសារទរ ជាមួយថ្នាក់ដឹកនាំនិងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់ អំពីលទ្ធផលការងារប្រមូលចំណូលពន្ធដារដែលសំរេចបានប្រចាំខែកញ្ញា ឆ្នាំ២០១៣ និង ជម្រុញការលើកទឹកចិត្តថ្នាក់ដឹកនាំគ្រប់អង្គភាពពន្ធដារ សមាជិកអង្គប្រជុំ ដែលជាតំណាងមន្ត្រី ពន្ធដារទូទាំងប្រទេសឲ្យខិតខំជំនះការលំបាកនិងបញ្ហាប្រឈមនានា ខិតខំអនុវត្តភារកិច្ចប្រមូល ចំណូលពន្ធគ្រប់ប្រភេទ ឲ្យបានសម្រេចតាមគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង បង្កើនការផ្តល់សេវាដល់អ្នកជាប់ពន្ធឲ្យបានប្រសើរ ផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធទទួលសេ វាងាយស្រួល ឆាប់រហ័សនៅគ្រប់ទីកន្លែង និងអនុវត្តវិធានការនានាសំដៅធ្វើឲ្យបានសម្រេចគោលដៅចំណូលឆ្នាំ២០១៣។

ក្នុងខែកញ្ញា ឆ្នាំ២០១៣នេះ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលនិងបង់ប្រាក់ពន្ធចូលថវិកាជាតិបានចំនួន ២៨៦,៩០០ លានរៀល (គិតជាដុល្លារប្រមាណ ៧១.៨លានដុល្លារ) ដោយមានការកើនឡើងជាងខែសីហា ឆ្នាំ២០១៣ ចំនួន ៩,៩២៩ លានរៀល។ បើប្រៀបធៀបទៅនឹងខែកញ្ញាដូចគ្នាក្នុងឆ្នាំ២០១២ មានការកើនឡើងស្មើនិង ២១.២%។ សរុបរយៈពេលប្រាំបួនខែក្នុងឆ្នាំ២០១៣ ចំណូលពន្ធអាករសរុបមានចំនួន ២,៧១២,២៣៩ លានរៀល (គិតជាដុល្លារប្រមាណ ៦៧៨.១ លានដុល្លារ) ស្មើនឹង៧៨.៣% នៃគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ក្នុងនោះថវិការដ្ឋសំរេចបានចំនួនស្មើនឹង ៧៥.៩% និងថវិការាជធានី-ខេត្ត សំរេចបានចំនួនស្មើនឹង ៩៦.៤%។ បើប្រៀបធៀបនឹងការអនុវត្តបានក្នុងរយៈពេលប្រាំបួនខែដូចគ្នាក្នុងឆ្នាំ២០១២ ឃើញថាក្នុងឆ្នាំ២០១៣ នេះមានការកើនឡើងចំនួនស្មើនឹងអត្រាកំណើន ១៧,៣%។

តាមការវិភាគប្រភេទពន្ធឃើញថា ចំណូលក្នុងឆ្នាំ២០១៣ មានការកើនឡើងគ្រប់ប្រភេទពន្ធ ក្នុងនោះប្រភេទពន្ធសំខាន់ៗដែលមានការកើនឡើងមានដូចជា ពន្ធលើប្រាក់បៀវត្សមានការកើនឡើងប្រមាណ២៤.៤% ពន្ធលើប្រាក់ចំណេញមានការកើនឡើងប្រមាណ ១៩.៥% អាករលើតម្លៃបន្ថែមមានការកើនឡើងប្រមាណ ១៨.១% និង អាករពិសេសមានការកើនឡើងប្រមាណ ១៦.១% ។

ការពិនិត្យតាមវិស័យឃើញថា ចំណូលក្នុងឆ្នាំ២០១៣ មានការកើនឡើងស្ទើរគ្រប់សកម្មភាព


អាគារកែងមហាវិថី សហព័ន្ធរុស្សី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
CORNER RUSSIAN FEDERATION & MAO TSETONG BLVD. TOEK LAAK 1, TOUL KAUK, PHNOM PENH
ទូរស័ព្ទ:(៨៥៥) ២៣ ៨៨៦ ៧០៨ / ទូរសារ:(៨៥៥) ២៣ ៨៨៦ ៧០០
Phone: (855) 23 886 708/ Fax: (885) 23 886 700

ក្នុងនោះ ផ្នែកផលិតភេសជ្ជៈកើនឡើងប្រមាណ២១.៩% ផ្នែកសេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២៧.៥% ផ្នែកទូរគមនាគមន៍កើនឡើងប្រមាណ ១៨.៦% ផ្នែកផលិតគ្រឿងប្រើប្រាស់កើនឡើងប្រមាណ ៣៤.៦% នីហរ័ណអាហារ័នកើនឡើងប្រមាណ ២២.២% ស្ថាបត្យកម្មនិងសំណង់កើនឡើងប្រមាណ ២២.១% ផ្នែកនីហរ័ណ-អាហរ័ណកើនឡើងប្រមាណ ២៤.២% ផ្នែកផលិតសម្លៀកបំពាក់កើនឡើងប្រមាណ៤៤.៦% ផ្នែកដឹកជញ្ជូននិងទេសចរណ៍កើនឡើងប្រមាណ ៣៤.៨% អាកាសយានដ្ឋាននិងកំពង់ផែកើនឡើងប្រមាណ ៧៣.៧% សណ្ឋាគារនិងផ្ទះសំណាក់កើនឡើងប្រមាណ ២២.៦% លក់គ្រឿងយន្តស្មើនឹង ២២៤.១% ផលិតម្ហូបអាហារស្មើនឹង ៤៩.២% និងផ្នែកផលិតគ្រឿងអេឡិចទ្រិចនិងអេឡិចត្រូនិច ស្មើនឹង ៤២.៧%។

ក្នុងការពិភាក្សាអង្គប្រជុំបានផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជា I-របាយការណ៍វឌ្ឍនភាពការងាររបស់នាយកដ្ឋាន សាខាពន្ធដារខេត្ត-ខណ្ឌ ស្តីពីការ ១-ការផ្ទេររបបម៉ៅការទៅរបបស្វ័យប្រកាស ២-ការប្រមូលពន្ធអចលនទ្រព្យ ៣-ការធ្វើសវនកម្ម ៤-ការប្រមូលបំណុលពន្ធនិងការចាត់ទុកបំណុលពន្ធមិនអាចទារបាន និងII-បញ្ហាផ្សេងៗ។

ដើម្បីគ្រប់គ្រងចំណូលពន្ធដារឱ្យមានស្ថេរភាពលើវិស័យមួយចំនួន ដែលមានសក្តានុពលចំណូលច្រើន អគ្គនាយកដ្ឋានពន្ធដារមាន គោលការណ៍និងទិសដៅដូចខាងក្រោម៖

- បន្តពង្រឹងការគ្រប់គ្រងប្រមូលពន្ធលើប្រាក់បៀវត្សរបស់បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងជាពិសេសតាមដានពន្ធលើអត្ថប្រយោជន៍បន្ថែមរបស់ក្រុមហ៊ុននិងអង្គការនានា។
- បន្តពង្រឹងការគ្រប់គ្រងព័ត៌មាននិងទិន្នន័យដើម្បីធ្វើការកំណត់ពន្ធឲ្យបានត្រឹមត្រូវ ចំពោះក្រុមហ៊ុនណាដែលប្រកាសពន្ធទាប និងប្រកាសបង់ពន្ធមិនបានត្រឹមត្រូវ ឲ្យមកប្រកាសបង់ពន្ធដោយតម្លាភាពត្រឹមត្រូវតាមច្បាប់។
- បន្តជំរុញនិងពិនិត្យសហគ្រាសបង់ពន្ធតាមរបបម៉ៅការ ដែលមានផលរបរច្រើនជាងការកំណត់នៃច្បាប់ឲ្យមកបង់ពន្ធតាមរបបស្វ័យប្រកាស ដើម្បីឲ្យការបង់ពន្ធស្មើភាពគ្នា។

ក្រៅពីកិច្ចការងារប្រមូលពន្ធដារ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងធ្វើកំណែទម្រង់សំខាន់ៗ ដូចជា៖ បាននិងកំពុងដាក់ម៉ាស៊ីនស្កេនម្រាមដៃ ដើម្បីតាមដានវត្តមាននិងអវត្តមានមន្ត្រីរាជការពន្ធដារទូទាំងប្រទេស និងបានរៀបចំមូលដ្ឋានគ្រឹះសម្រាប់ធ្វើការវាយតម្លៃនិងតាមដានប្រសិទ្ធភាពការងារលើកិច្ចការរបស់មន្ត្រី និងកំពុងទាក់ទងធនាគារ ANZ ROYAL និង WING វេរលុយ ដើម្បីបើកគណនីសម្រាប់ថ្នាក់ដឹកនាំមន្ត្រីរាជការពន្ធដារគ្រប់រូប។

ជាកិច្ចបញ្ចប់ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃ អគ្គនាយកដ្ឋានពន្ធដារ បានវាយតម្លៃខ្ពស់ដល់គ្រប់អង្គភាពពន្ធដារ ដែលបានប្រឹងប្រែងខិតខំប្រមូលចំណូលដែលមានការកើនឡើងគួរជាទីពេញចិត្ត និងផ្តល់អនុសាសន៍ណែនាំបន្ថែមដល់អស់លោកជាប្រធានអង្គភាពពន្ធដារគ្រប់លំដាប់ថ្នាក់ និងមន្ត្រីពន្ធដារទាំងអស់ ខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារឲ្យបានល្អប្រសើរ តាមរយៈការផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយប្រសិទ្ធភាព និងភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ដោយគោរពច្បាប់និងបទប្បញ្ញត្តិជាគោល ធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធរីករាយក្នុងកិច្ចសហការបង់ពន្ធជូនរដ្ឋ និងកិច្ចពង្រឹងរដ្ឋបាលសារពើពន្ធដើម្បីការប្រមូលពន្ធឲ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ថែមទៀត ដើម្បីឈានទៅសំរេចបានតាមផែនការក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។

**អគ្គនាយកដ្ឋានពន្ធដារ**